ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៤៣៤ ប្រ.ក

# ប្រកាស
## ស្តីពី
## ការរៀបចំបង្កើតលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៥អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពដូចខាងក្រោម ៖

**ក. លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ៖**

| | | |
|---|---|---|
| ១. | អភិបាលរង០១រូប | ប្រធាន |
| ២. | នាយករដ្ឋបាល | អនុប្រធាន |
| ៣. | ស្នងការរងនគរបាល | សមាជិក |
| ៤. | មេបញ្ជាការរងកងរាជអាវុធហត្ថ | សមាជិក |
| ៥. | មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករង | សមាជិក |
| ៦. | តំណាងមន្ទីរ អង្គភាពពាក់ព័ន្ធ | សមាជិក |

**ខ. លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៖**

| | | |
|---|---|---|
| ១. | អភិបាលរង០១រូប | ប្រធាន |
| ២. | នាយករដ្ឋបាល | អនុប្រធាន |
| ៣. | អធិការរងនគរបាល | សមាជិក |
| ៤. | មេបញ្ជាការរងកងរាជអាវុធហត្ថ | សមាជិក |
| ៥. | មេបញ្ជាការរងផ្នែកសឹករង | សមាជិក |
| ៦. | តំណាងការិយាល័យ អង្គភាពពាក់ព័ន្ធ | សមាជិក |

**ប្រការ ២.-**

លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

- រៀបចំសេចក្តីព្រាងផែនការសកម្មភាព ថវិកា និងកម្មវិធីការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនគណៈបញ្ជាការឯកភាពពិនិត្យ និងសម្រេច
- រៀបចំកិច្ចប្រជុំនានារបស់គណៈបញ្ជាការឯកភាព និងរៀបចំកំណត់ហេតុកិច្ចប្រជុំ
- សហការតាមដានសភាពការណ៍ សកម្មភាពបទល្មើសនានា និងការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីរាយការណ៍សុំយោបល់ដឹកនាំពីប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី
- តាមដាន ត្រួតពិនិត្យលទ្ធផលនៃការអនុវត្តគោលការណ៍ ផែនការសកម្មភាព និងសេចក្តីសម្រេចនានារបស់គណៈបញ្ជាការឯកភាព និងធ្វើសេចក្តីរាយការណ៍ជូនគណៈបញ្ជាការឯកភាព ដើម្បីបន្តដឹកនាំឲ្យមានប្រសិទ្ធភាព

- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារតាមដំណាក់កាលនីមួយៗ ឬរបាយការណ៍រឿងហេតុជាក់លាក់ជូនគណៈបញ្ជាការឯកភាព ដើម្បីរាយការណ៍បន្តជូនក្រសួងមហាផ្ទៃ ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ដឹកនាំទាន់ពេលវេលា
- បំពេញការងាររដ្ឋបាល លិខិតស្នាម និងរក្សាទុកឯកសាររបស់គណៈបញ្ជាការឯកភាព។

**ប្រការ ៣.-**

ការបង្កើតលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី។

លេខាធិការដ្ឋាននេះ មានការិយាល័យធ្វើការរបស់ខ្លួននៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី។

**ប្រការ ៤.-**

លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្រើប្រាស់មន្ត្រីដទៃទៀតនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី និងមន្ត្រីមន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីជួយបំពេញការងាររបស់ខ្លួន។

**ប្រការ ៥.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអង្គភាពដែលមានការពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងនៅក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**<u>កន្លែងទទួល</u> ÷**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *ដូចប្រការ៥*
- *ឯកសារ កាលប្បវត្តិ*